# កម្មវិធីជួបជុំអ្នកទទួលផលពីគម្រោងកែលម្អកម្រិតជីវភាពគ្រួសារកសិករស្រុកកំពង់ត្រឡាច និងសាមគ្គីមានជ័យ និងពិព័រណ៍ផលិតផលកសិកម្មតាមគោលការណ៍ធម្មជាតិ

នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ នៅក្នុងបរិវេណសាលាបឋមសិក្សា សាលាលេខប្រាំ ឃុំអូរបស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង សេដាក សហការជាមួយមន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង និងអាជ្ញាធរស្រុកកំពង់ត្រឡាចបាន ប្រារព្ធពិធីជួប ជុំកសិករទទួលផលពីគំរោងនិងតាំងពិព័ណ៌សមិទ្ធិផលរបស់កសិកររយៈពេលពេញមួយថ្ងៃ ។

កសិករប្រមាណ ៩០០ នាក់មកពីស្រុងកំពង់ត្រឡាច ស្រុកសាមគ្គីមានជ័យ និងស្រុករលាប្អៀរ បានចូលរួមក្នុង កម្មវិធីនេះ ។ អ្នកចូលរួមផ្សេងទៀតរួមមានៈ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិបាលខេត្ត កំពង់ឆ្នាំង ប្រធានអង្គការ សេដាក ប្រធានអង្គការសប្បុរសពួកបរិសុទ្ធថ្ងៃចុងក្រោយប្រចាំប្រទេសកម្ពុជា អភិបាលស្រុក កំពង់ត្រឡាច និងសាមគ្គីមានជ័យ ប្រធានមន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង ប្រធានមន្ទីរពាក់ព័ន្ធ ប្រធានការិយាល័យកសិកម្មស្រុក កំពង់ត្រឡាច និងសាមគ្គីមានជ័យ មេឃុំ និងមេភូមិ គ្រប់ភូមិឃុំ តំណាងសមាគមកសិករ តំណាងអង្គការក្រៅរដ្ឋាភិបាល ដែលកំពុង ប្រតិបត្តិនៅក្នុងស្រុកកំពង់ត្រឡាច និងសាមគ្គីមានជ័យ ក៏បានចូលរួមក្នុងកម្មវិធីនេះផងដែរ ។

កម្មវិធីនេះប្រារព្ធឡើងក្នុងគោលបំណងដើម្បីធ្វើការអបអរសាទរនូវសមិទ្ធិផលដែលកសិករសំរេចបានក្នុងរយៈពេល បីឆ្នាំកន្លងមក និង បង្កើននូវការយល់ដឹងរបស់កសិករ ក៏ដូចជាអ្នកបរិភោគអំពីផលិតផលកសិកម្មតាមគោលការណ៍ ធម្មជាតិ ។

នៅក្នុងអំឡុងកម្មវិធីជួបជុំនោះ លោកបណ្ឌិតយ៉ង សាំងកុមារប្រធានកអង្គការ សេដាក បានមានប្រសាសន៍គូសបញ្ជាក់ អំពីការសំរេចបានសំខាន់ៗរបស់គម្រោងកែលម្អកម្រិតជីវភាពគ្រួសារកសិករស្រុកកំពង់ត្រឡាច និងសាមគ្គីមានជ័យក្នុងរយៈ ពេលបីឆ្នាំនេះ ដែលរួមមាន ៖

- ការអនុវត្តនូវបច្ចេកទេសប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ប.វ.ស
- ការសន្សំប្រាក់ដើម្បីភាពអាស្រ័យលើខ្លួនឯង ដែលបច្ចុប្បន្នមានក្រុមសន្សំប្រាក់ចំនួន ២១០ ក្រុម និង
- ការដាំបន្លែជាលក្ខណៈគ្រួសារ ។

ក្រៅពីនេះ លោកក៏បានសំណូមពរទៅដល់ប្រជាកសិករឱ្យយកចិត្តទុកដាក់ទៅលើចំនុចសំខាន់ចំនួនពីរគឺ ការគិតគូរពី ជីជាតិដី ដោយការដាក់ ឬប្រើប្រាស់ជីធម្មជាតិ និងការស្វែងនូវសំណាបថ្លោស ដោយចាប់តិច និងស្ទូងរាក់ ។

គួរបញ្ជាក់ថា តាមរយៈការអនុវត្តន៏គម្រោងរយៈពេល ៣ ឆ្នាំយើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា គម្រោងបានអនុវត្តស្រប ទៅតាមផែនការដែលបានគ្រោងទុក។ ជាលទ្ធផលឃើញថាកសិករប្រមាណជា ៣២៧៦ គ្រួសារបាននឹងកំពុង ទទួលផល ពីគម្រោងក្នុងការអនុវត្តន៏បច្ចេកទេសកសិកម្មតាមគោលការណ៏ធម្មជាតិ និងជាសមាជិកនៃក្រុមផ្សេងៗ ដូចជា ក្រុមផលិត ក្រុមសន្សំប្រាក់ ក្រុមយុវជន ក្រុមក្រីក្រ ក្រុមស្ត្រី និងផ្សារសហគមន៏ជាដើម ហើយប្រាក់ចំណូលរបស់ពួកគេមានការកើន ឡើងជាងមុនផងដែរ ។

